ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃអង្គារ ៥កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ ២០២២ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានដំណើរការសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០២២ និងលើកទិសដៅការងារឆ្នាំ ២០២៣ ដោយមានអ្នកចូលរួមសរុបប្រមាណ ២ ០០០ នាក់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងពិធីបិទ។ បន្ទាប់ពីការអានរបាយការណ៍លទ្ធផលសន្និបាតដោយ **ឯកឧត្តម ជា សុផារ៉ា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្តេចតេជោនាយករដ្ឋមន្ត្រី** បានមានប្រសាសន៍កោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះលទ្ធផលដែលក្រសួងសម្រេចបានក្នុងឆ្នាំ២០២២ សមិទ្ធផលថ្មីៗជាច្រើនដែលជាជោគជ័យរបស់រាជរដ្ឋាភិបាលក្រោមម្លប់នៃសន្តិភាព និងបានដាក់ចេញនូវទិសដៅការងារសម្រាប់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបន្តយកចិត្តទុកដាក់អនុវត្តនៅឆ្នាំ ២០២៣ ដូចខាងក្រោម÷

១. បន្តអនុវត្តផែនការចុះបញ្ជីដី រួមទាំងការចុះបញ្ជីដីរដ្ឋ ដីសាធារណៈរបស់រដ្ឋ ដីសម្បទានសេដ្ឋកិច្ច ដីរដ្ឋជុំវិញបឹងទន្លេសាប និងដីសហគមន៍ជនជាតិដើមភាគតិច ដើម្បីធានានូវសុវត្ថិភាពនៃការកាន់កាប់ដីធ្លីដែលជាទុនផ្តល់ដោយរាជរដ្ឋាភិបាលជូនប្រជាពលរដ្ឋសម្រាប់រស់នៅ ដាំដុះ និងវិនិយោគ បង្កើតមុខរបរ និងបង្កើនប្រាក់ចំណូល។ ជាមួយនឹងការសម្រេចបានរហូតមកដល់បច្ចុប្បន្នចំនួន ៩៦,២០% នៃក្បាលដីប៉ាន់ស្មានដំបូង ៧លានក្បាលដី ត្រូវរួសរាន់បញ្ចប់ការចុះបញ្ជីក្បាលដីដែលនៅសល់។

២. ជំរុញការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ ដោយឈរលើគោលការណ៍អព្យាក្រឹត្យ មិនលម្អៀងលើភាគីវិវាទណាមួយ ដើម្បីពង្រឹងសុវត្ថិភាពនៃការកាន់កាប់ដី បង្កើតភាពសុខដុមរមនាសង្គម និងបង្កភាពអនុគ្រោះដល់ដំណើរការនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចនៅតាមមូលដ្ឋាន។

៣. ពង្រីកវិសាលភាពនៃការអនុវត្តគម្រោងសាងសង់ស្ថានីយវាស់វែងអចិន្ត្រៃយ៍ដោយផ្កាយរណបសម្រាប់ការគ្រប់គ្រងដី និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឱ្យបានទូទាំងប្រទេស។

៤. ពង្រឹងការអនុវត្តច្បាប់ស្តីពីសំណង់ ទាំងលើការងារសាងសង់ និងការត្រួតពិនិត្យសំណង់ ដើម្បីធានាបង្កើនគុណភាព សុវត្ថិភាព និងសុខុមាលភាពរបស់ម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់ និងសាធារណជននិងចូលរួមការពារសំណង់បេតិកភណ្ឌ តាមរយៈការជំរុញការចុះបញ្ជីទីតាំងតំបន់ការពារបុរាណដ្ឋានជូនក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

៥. បន្តបែងចែកដី និង/ឬផ្ទះ សម្រាប់គោលដៅសម្បទានសង្គមកិច្ចជូនប្រជាពលរដ្ឋ អតីតយុទ្ធជន និងកងកម្លាំងប្រដាប់អាវុធ និងបន្តគាំទ្រដល់ការអនុវត្តគម្រោងសាងសង់លំនៅឋានតម្លៃសមរម្យ សំដៅលើកកម្ពស់សិទ្ធិទទួលបានលំនៅឋានរបស់ប្រជាពលរដ្ឋ។

៦. ជំរុញការអភិរក្សនៅតំបន់រមណីយដ្ឋានអង្គរ ស្របគ្នានឹងការអភិវឌ្ឍនៅតំបន់អភិវឌ្ឍនទាឯក និងតំបន់អភិវឌ្ឍពាក់ស្នែង ជូនបងប្អូនប្រជាពលរដ្ឋដែលស្ម័គ្រចិត្តចាកចេញពីតំបន់រមណីយដ្ឋានអង្គរទៅតាំងទីលំនៅថ្មីនៅតំបន់នោះ ដោយអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវគោលនយោបាយគាំទ្រផ្នែកសង្គមកិច្ច និងផ្នែកហេដ្ឋារចនាសម្ព័ន្ធដែលរាជរដ្ឋាភិបាលបានដាក់ចេញ។

៧. បន្តដោះស្រាយជូនប្រជាជនដែលរស់នៅជាភូមិករនៅជុំវិញបឹងទន្លេសាប ដោយធ្វើបច្ចុប្បន្នភាពផែនទីតាមខេត្តនីមួយៗជុំវិញបឹងទន្លេសាប ស្របតាមស្ថានភាពនៃការកែសម្រួលព្រំប្រទល់តំបន់ ៣ ព្រំប្រទល់តំបន់ ២ និងកាត់ឆ្វៀលទីតាំងដីដែលប្រជាជនរស់នៅពីយូរលង់មកហើយក្នុងតំបន់ ៣ និងតំបន់ ២ ឱ្យចប់ត្រឹមខែឧសភា ឆ្នាំ ២០២៣។

៨. ជំរុញការរៀបចំផែនការអភិរក្ស ការពារ និងអភិវឌ្ឍតំបន់ឆ្នេរ ដើម្បីគាំទ្រដល់ការអភិរក្សនិងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជាប្រកបដោយប្រសិទ្ធភាព ចីរភាព និងសមធម៌ ឱ្យស័ក្តិសមជាឆ្នេរសមុទ្រដែលស្អាតបំផុតលើសាកលលោក និងជាតារានៅទិសនិរតី។

៩. បន្តពង្រឹង និងកែលម្អការផ្តល់សេវាសាធារណៈគ្រប់ប្រភេទ ដោយជំរុញអនុវត្តឱ្យបានតាមទិសស្លោក "ធ្វើឱ្យបាន ធ្វើឱ្យលឿន និងមានតម្លាភាព" ក្នុងការផ្តល់សេវាសាធារណៈជូនដល់ប្រជាពលរដ្ឋ យកចិត្តទុកដាក់ដោះស្រាយរាល់សំណើនិងសំណូមពរ និងខិតខំកាត់បន្ថយការចំណាយរបស់ប្រជាជន។

ឆ្លៀតក្នុងឱកាសនេះដែរ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានអញ្ជើញកាត់ខ្សែបូសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារមន្ទីរពិសោធន៍ជាតិសំណង់ ដែលស្ថិតនៅក្នុងបរិវេណទីស្តីការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

អាស្រ័យហេតុនេះ សូមសាធារណជនជ្រាបជាព័ត៌មាន។

ថ្ងៃអង្គារ ៥កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ ២០២២